**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៤០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.- គោលបំណង**

អនុក្រឹត្យនេះមានគោលបំណងផ្តល់ការលើកទឹកចិត្តពន្ធដារ ដើម្បីអភិវឌ្ឍវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីប្រភេទ សកម្មភាព និងលក្ខខណ្ឌនានា ដែលជាកម្មវត្ថុនៃការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩។

**មាត្រា២.- វិសាលភាព**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះ÷

១.ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា (សរសេរកាត់ថា **ន.ម.ក.**) និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។

២.មូលបត្ររដ្ឋ ដែលសំដៅដល់បណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុលដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល ដូចដែលបានបញ្ញត្តនៅក្នុងមាត្រា៣ នៃច្បាប់ស្តីពីមូលបត្ររដ្ឋ។

៣.អ្នកវិនិយោគសាធារណៈ ដែលកាន់កាប់ និង/ ឬ ទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ ឬ មូល-បត្របំណុលដែលបានបោះផ្សាយលក់ជាសាធារណៈ និងបានចុះបញ្ជីនៅទីផ្សារមូលបត្រប្រតិស្រុត។ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ អ្នកវិនិយោគសាធារណៈរួមបញ្ចូលទាំងអ្នកវិនិយោគនិវាសនជននិងអនិវាសនជន។

## ជំពូកទី២

## សកម្មភាព និងលក្ខខណ្ឌនៃការលើកទឹកចិត្តពន្ធដារ

**មាត្រា៣.-** ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបំពេញបែបបទជូនអគ្គនាយកដ្ឋានពន្ធដារតាមរយៈ **គ.ម.ក.** នៅរាល់មុនកាលបរិច្ឆេទបង់ពន្ធសម្រាប់ឆ្នាំសារពើពន្ធនីមួយៗដើម្បីទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលតាមលក្ខខណ្ឌដូចមានកំណត់ក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ ក្នុងរយៈពេលនៃការទទួលបានការលើកទឹកចិត្តពន្ធដារ ដូចមានកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា៣ នៃអនុក្រឹត្យនេះ។

ការលើកទឹកចិត្តពន្ធដារមានរយៈពេល ៣ (បី) ឆ្នាំ និងត្រូវគិតចាប់ផ្ដើមពី÷

១-ដើមឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះ-ផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ដើមឆ្នាំជាប់ពន្ធនោះ។

២-ដើមឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ចុងឆ្នាំជាប់ពន្ធ។

៣-អំឡុងពេលណាមួយដែលទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤.-** លក្ខខណ្ឌដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល ត្រូវបានកំណត់អំពីលក្ខខណ្ឌដូចខាងក្រោម÷

១-ក្រុមហ៊ុន/ សហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំលើសពី ២០ (ម្ភៃ) ភាគរយ នៃសិទ្ធិបោះឆ្នោត និង/ ឬ បោះផ្សាយមូលបត្របំណុលក្នុងទំហំលើសពី ២០(ម្ភៃ) ភាគរយ នៃទ្រព្យសកម្មសរុប និងមានឥណប្រតិទានយ៉ាងតិច ៧ (ប្រាំពីរ) ឆ្នាំ នឹងទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលចំនួន ៥០ (ហាសិប) ភាគរយ នៃពន្ធលើប្រាក់ចំណូលត្រូវបង់។

២-ក្រុមហ៊ុន/ សហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំ ២០(ម្ភៃ) ភាគរយ ឬតិចជាង នៃសិទ្ធិបោះឆ្នោត និង/ ឬ បោះផ្សាយមូលបត្របំណុលក្នុងទំហំ ២០ (ម្ភៃ) ភាគរយ ឬ តិចជាងនៃទ្រព្យសកម្មសរុបនឹងទទួលបាននូវការលើកទឹកចិត្តពន្ធតាមសមាមាត្រចុះដោយយក ២០,០០១ ជាគោល ( ដូចមានក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ) ដែលក្នុងនោះ÷

- ការបោះផ្សាយមូលបត្រកម្មសិទ្ធិ÷ ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលតាមសមាមាត្រ មិនឱ្យលើសពី ២០ (ម្ភៃ) ប៊ីលានរៀល។

- ការបោះផ្សាយមូលបត្របំណុល÷ ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលតាមសមាមាត្រ មិនឱ្យលើសពី ៨ (ប្រាំបី) ប៊ីលានរៀល។

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលជាសាធារណៈ ដើម្បីទទួលបានហិរញ្ញប្បទានក្នុងគោលដៅនៃការអភិវឌ្ឍបៃតង និងប្រកបដោយចីរភាព ឬការអភិវឌ្ឍក្នុងវិស័យអាទិភាពណាមួយ នឹងទទួលបានការលើកទឹកចិត្តពន្ធដារពិសេសបន្ថែម តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥.- ការអនុគ្រោះបំណុលពន្ធចំពោះក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ**

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវទទួលបានការអនុគ្រោះបំណុលពន្ធដែលរួមបញ្ចូលពន្ធលើប្រាក់ចំណូលទាំងស្រុង ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ។ ការអនុគ្រោះបំណុលពន្ធទាំងស្រុងត្រូវអនុវត្តដូចខាងក្រោម÷

១- បំណុលពន្ធចាប់ពីកាលបរិច្ឆេទ N-3 ដល់ N-10 សម្រាប់ក្រុមហ៊ុន/ សហគ្រាសដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារគោល។

២- បំណុលពន្ធចាប់ពីកាលបរិច្ឆេទ N-2 ដល់ N-10 សម្រាប់សហគ្រាសធុនតូច និងមធ្យមដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារកំណើន។ (ឆ្នាំ N គឺជាឆ្នាំដែលក្រុមហ៊ុន/ សហគ្រាសធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលជាសាធារណៈជាលើកដំបូង។)

ការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនតម្រូវឱ្យមានការធ្វើសវនកម្មពេញលេញជាមុនពីអគ្គនាយកដ្ឋានពន្ធដារនោះទេ។ សម្រាប់ការស្នើសុំបោះផ្សាយ ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈត្រូវផ្តល់ជូន **ន.ម.ក.** នូវវិញ្ញាបនបត្របញ្ជាក់កាតព្វកិច្ចពន្ធចេញ

ដោយអគ្គនាយកដ្ឋានពន្ធដារ ដែលជាលិខិតសម្រាប់បញ្ជាក់ពីការប្រកាស និងបង់ពន្ធជាប្រចាំដោយមិនទាន់រងការធ្វើសវនកម្មពីអគ្គនាយកដ្ឋានពន្ធដារ។

**មាត្រា៦.-ការលើកទឹកចិត្តពន្ធកាត់ទុក និងពន្ធលើចំណេញមូលធនដល់អ្នកវិនិយោគមូលបត្រ**

អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយលើការប្រាក់ និង/ឬ ភាគលាភដែលបានមកពីការកាន់កាប់ និង/ឬ ការទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល និងត្រូវបានលើកលែងពន្ធលើចំណេញមូលធន ចំពោះការទិញ និងការជួញដូរមូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលសម្រាប់រយៈពេល ៣(បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

បុគ្គលជាភ្នាក់ងារកាត់ទុកដែលធ្វើការបើកការប្រាក់ និង/ឬ ភាគលាភត្រូវធ្វើការគណនាប្រាក់ពន្ធកាត់ទុកដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ មុនការបើកប្រាក់ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០(ម្ភៃ) នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក។

ការកំណត់អត្រាពន្ធលើការប្រាក់នៃមូលបត្ររដ្ឋ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧.- ក្រុមហ៊ុន/សហគ្រាសដែលមិនត្រូវបានទទួលការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល**

ក្រុមហ៊ុន/សហគ្រាសមិនត្រូវទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងមាត្រា៣ និងមាត្រា៥ នៃអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុននោះជាសហគ្រាសវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលកំពុងស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨.-ការបញ្ឈប់ និងការដកហូតការលើកទឹកចិត្តពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារអាចស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈ **គ.ម.ក.** ដើម្បីបញ្ឈប់ និងដកហូតការលើកទឹកចិត្តពន្ធដារដូចមានចែងក្នុងមាត្រា៣ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ក្នុងករណីក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត÷

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ និងបង់ប្រាក់ពន្ធ តាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ។

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធ និងបង់ប្រាក់ពន្ធតាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ។ លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រ រួមមាន តារាងតុល្យការ គណនីលទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ដោយមិនឱ្យហួសពីរយៈពេល ៣(បី) ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ។

- មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើសវនកម្មលើបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ។

- មិនបានបង់ពន្ធអាករទាំងអស់ ពន្ធបន្ថែម និងការប្រាក់ ដែលបានកំណត់សម្រាប់រយៈពេលជាប់ពន្ធដែលបានធ្វើសវនកម្មរួចដោយរដ្ឋបាលសារពើពន្ធ។

- អគ្គនាយកដ្ឋានពន្ធដាររកឃើញថាក្រុមហ៊ុន/សហគ្រាសមានចេតនាគេចវេះពន្ធ តាមរយៈការបោះផ្សាយមូលបត្រលើកដំបូងជាសាធារណៈ។

ក្នុងករណីក្រុមហ៊ុន/សហគ្រាសដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងអនុក្រឹត្យនេះ មិនបានអនុវត្តតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យមូលបត្រ **ន.ម.ក.** អាចស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបញ្ឈប់ការលើកទឹកចិត្តដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៣ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ។

ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្របុរិស្រុតមិនត្រូវទទួលបាននូវការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុន/-សហគ្រាសនោះបានដកខ្លួនចេញពីការចុះបញ្ជី ឬត្រូវបានដកពីការចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្របុរិស្រុត។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា៩.- ការលើកទឹកចិត្តពន្ធដារចំពោះក្រុមហ៊ុន/សហគ្រាសដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈរួច**

ក្រុមហ៊ុន/សហគ្រាសដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** ធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងដែលបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្របុរិស្រុតរួចហើយ តែមិនទាន់ទទួលបាននូវការលើកទឹកចិត្តពន្ធដារនោះ ត្រូវបានផ្តល់ការលើកទឹកចិត្តពន្ធដារដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ។

**មាត្រា១០.- ការជំនួស**

បញ្ញត្តិទាំងឡាយដែលចេញឡើងស្របតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រនឹងត្រូវបន្តអនុវត្តអនុលោមតាមអនុក្រឹត្យនេះ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១.-** ការអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែអាសាឍ ឆ្នាំជូត ត្រីស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ

## នៃអនុក្រឹត្យលេខ ........ អនក្រ.បក ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ........

## ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

* * * *

### តារាងសមាមាត្រក្នុងការផ្តល់ការលើកទឹកចិត្តពន្ធដារ ដោយយកទំហំនៃការបោះផ្សាយ ២០,០០១* ជាគោល

| ល.រ | ទំហំបោះផ្សាយ | សមាមាត្រភាគរយនៃការលើកទឹកចិត្តទទួលបាន | ភាគរយនៃការលើកទឹកចិត្តលើប្រាក់ពន្ធត្រូវបង់ប្រចាំឆ្នាំ (ដូចក្នុងអនុក្រឹត្យ) |
|---|---|---|---|
| | A | B = A / 20.001% | C = B * 50% |
| 1 | ចាប់ពី 20.001% | 100.000% | 50.000% |
| 2 | 20.000% | 99.995% | 49.9975% |
| 3 | 19.500% | 97.495% | 48.748% |
| 4 | 19.000% | 94.995% | 47.498% |
| 5 | 18.500% | 92.495% | 46.248% |
| 6 | 18.000% | 89.996% | 44.998% |
| 7 | 17.500% | 87.496% | 43.748% |
| 8 | 17.000% | 84.996% | 42.498% |
| 9 | 16.500% | 82.496% | 41.248% |
| 10 | 16.000% | 79.996% | 39.998% |
| 11 | 15.500% | 77.496% | 38.748% |
| 12 | 15.000% | 74.996% | 37.498% |
| 13 | 14.500% | 72.496% | 36.248% |
| 14 | 14.000% | 69.997% | 34.998% |
| 15 | 13.500% | 67.497% | 33.748% |
| 16 | 13.000% | 64.997% | 32.498% |
| 17 | 12.500% | 62.497% | 31.248% |
| 18 | 12.000% | 59.997% | 29.999% |
| 19 | 11.500% | 57.497% | 28.749% |
| 20 | 11.000% | 54.997% | 27.499% |
| 21 | 10.500% | 52.497% | 26.249% |
| 22 | 10.000% | 49.998% | 24.999% |

| | | | |
|---|---|---|---|
| 23 | 9.500% | 47.498% | 23.749% |
| 24 | 9.000% | 44.998% | 22.499% |
| 25 | 8.500% | 42.498% | 21.249% |
| 26 | 8.000% | 39.998% | 19.999% |
| 27 | 7.500% | 37.498% | 18.749% |
| 28 | 7.000% | 34.998% | 17.499% |
| 29 | 6.500% | 32.498% | 16.249% |
| 30 | 6.000% | 29.999% | 14.999% |
| 31 | 5.500% | 27.499% | 13.749% |
| 32 | 5.000% | 24.999% | 12.499% |
| 33 | 4.500% | 22.499% | 11.249% |
| 34 | 4.000% | 19.999% | 10.000% |
| 35 | 3.500% | 17.499% | 8.750% |
| 36 | 3.000% | 14.999% | 7.500% |
| 37 | 2.500% | 12.499% | 6.250% |
| 38 | 2.000% | 10.000% | 5.000% |
| 39 | 1.500% | 7.500% | 3.750% |
| 40 | 1.000% | 5.000% | 2.500% |

សម្គាល់÷

$$\text{ភាគរយនៃការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល} = \frac{\text{ទំហំបោះផ្សាយធៀបនឹងសិទ្ធិបោះឆ្នោតសរុប ឬទ្រព្យសកម្មសរុប}}{\text{ទំហំបោះផ្សាយគោល (20.001\%)}} \times 50\%$$

* សម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិ÷ ទំហំបោះផ្សាយត្រូវធៀបនឹងចំនួនមូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតសរុប។
* សម្រាប់ការបោះផ្សាយមូលបត្របំណុល÷ ទំហំបោះផ្សាយត្រូវធៀបនឹងទ្រព្យសកម្មសរុប។

---